ព្រឹត្តិបត្រវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងកម្ពុជា

លេខទី 4 | សីហា 2016

International Labour Organization

# និន្នាការតម្លៃនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងនៅកម្ពុជា និងផលប៉ះពាល់តាមរយៈប្រាក់ឈ្នួល និងលក្ខខណ្ឌការងារ

## ផ្នែកទី I ៖តម្លៃនាំចេញ

**វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងកម្ពុជាផ្តោតសំខាន់លើការនាំចេញ និងមានសមាហរណកម្មខ្ពស់ទៅនឹងខ្សែសង្វាក់ផ្គត់ផ្គង់សកល។ តម្លៃដែលផ្តល់ដល់ផលិតផលនាំចេញពីកម្ពុជា មានផលប៉ះពាល់ខ្លាំងដល់ស្ថានភាពរបស់វិស័យ រួមបញ្ចូលទាំងថ្លៃឈ្នួលពលកម្មដែលរោងចក្រត្រូវរ៉ាប់រងផងដែរ។ តម្លៃសម្រាប់ការនាំចេញទៅកាន់ទីផ្សារសំខាន់ៗ បាននៅទ្រឹងក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ប្រសិនបើនិន្នាការនេះនៅតែបន្ត វាអាចមានការប៉ះពាល់ខ្លាំងតាមរយៈប្រាក់ឈ្នួល និងលក្ខខណ្ឌការងារ។**

ច្បាប់ទីបួននៃព្រឹត្តិបត្រវិស័យកាត់ដេរនិងស្បែកជើងកម្ពុជារបស់អង្គការអន្តរជាតិខាងការងារ នឹងធ្វើការពិនិត្យមើលជាក់លាក់មួយលើតម្លៃនាំចេញ។ ការវិភាគនេះផ្អែកលើស្ថិតិរបស់ប្រភពផ្លូវការដែលបានមកពី នាយកដ្ឋានការងារ និង នាយកដ្ឋានពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក ស្ថិតិសហភាពអឺរ៉ុប (Eurostat) និង ក្រសួងពាណិជ្ជកម្ម ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាភិបាលវិនិយោគកម្ពុជា អគ្គនាយកដ្ឋានពន្ធគយនិងអាករ វិទ្យាស្ថានជាតិស្ថិតិ និង ធនាគារជាតិនៃកម្ពុជា [1] ។ ផ្នែកទីមួយនៃព្រឹត្តិបត្រនេះ សំដៅលើការវិវត្តនៃតម្លៃនាំចេញ។ ផ្នែកទីពីរ រួមមានព័ត៌មានបច្ចុប្បន្នភាពជាប្រចាំនៃស្ថិតិសំខាន់ៗ។

### I. និន្នាការតម្លៃនាំចេញសម្លៀកបំពាក់និង ស្បែកជើង

វិស័យកាត់ដេរនិងស្បែកជើងក្នុងពិភពលោកមានការប្រកួតប្រជែងខ្ពស់។ កំណើននៃការផ្គត់ផ្គង់ពីប្រទេសផលិតសំខាន់ៗដូចជា ចិន វៀតណាម និង បង់ក្លាដេស បានដាក់សម្ពាធរុញចុះដល់តម្លៃសម្លៀកបំពាក់សម្រាប់ទីផ្សារសំខាន់ៗ ក្នុងអំឡុងរយៈពេល 10-15 ឆ្នាំនេះ។ ក្នុងនោះមាន ទីផ្សារសហរដ្ឋអាមេរិក និង អឺរ៉ុបដែលជាទីផ្សារសំខាន់របស់អ្នកនាំចេញកម្ពុជា។

**រូបភាពទី I ៖ សន្ទស្សន៍តម្លៃនាំចេញសម្លៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសំខាន់ៗ (2012=100)**




ប្រភព៖ អគ្គនាយកដ្ឋានពន្ធគយនិងអាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

តម្លៃជាមធ្យមដែលទទួលបានសម្រាប់ការនាំចេញពីកម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក បានធ្លាក់ចុះក្នុងទសវត្សកន្លងទៅ។ តម្លៃសម្រាប់ការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកបានធ្លាក់ចុះ 23.7 ភាគរយ ក្នុងរវាងឆ្នាំ 2006 និង 2015[2] ។ តម្លៃជាមធ្យមបាននៅទ្រឹងក្នុងឆ្នាំ 2015 ប៉ុន្តែបានបន្តធ្លាក់ចុះទៀត នៅក្នុងត្រី

[1] អង្គការពលកម្មអន្តរជាតិ សូមទទួលស្គាល់និងអរគុណក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាវិនិយោគកម្ពុជា និង វិទ្យាស្ថានជាតិស្ថិតិ ចំពោះការជួយគាំទ្រ និង ទិន្នន័យដែលបានប្រើនៅក្នុងព្រឹត្តិបត្រនេះ។ កំហុសទាំងឡាយបើមាន គប្បីត្រូវសន្មតថាជារបស់អង្គការពលកម្មអន្តរជាតិ។

[2] ការគណនារបស់អង្គការអន្តរជាតិខាងការងារយោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធគយនិងអាករ

មាសដំបូងនៃឆ្នាំ 2016 ។ តម្លៃមធ្យមសម្រាប់ការនាំចេញសម្លៀកបំពាក់កម្ពុជា ទៅកាន់ទីផ្សារអឺរ៉ុប បានបន្តធ្លាក់ចុះក្នុងអំឡុងទសវត្សចុងក្រោយ ប៉ុន្តែការធ្លាក់ចុះមិនខ្លាំងពេកទេ។

កម្ពុជាមិនមានសន្ទស្សន៍តម្លៃនាំចេញសម្លៀកបំពាក់ជាផ្លូវការទេ។ ក៏ប៉ុន្តែ យើងអាចធ្វើការគណនាតម្លៃមធ្យមនៃការនាំចេញសម្លៀកបំពាក់ដោយធ្វើការចែកតម្លៃការនាំចេញនឹងបរិមាណនាំចេញ ដូចបង្ហាញក្នុងរូបទី 1។ នេះមិនមែនជាវិធានសុក្រិតទេ ដោយហេតុថាវាមិនបានគិតគូដល់សមាសធាតុនាំចេញ និង គុណភាពនាំចេញនោះទេ ដែលសន្ទស្សន៍នាំចេញតែងតែគ្រប់គ្រងកត្តាទាំងនេះ។ ទោះជាយ៉ាងនេះក្តី វាអាចប្រើជាសូចនាករនិន្នាការតម្លៃបានក្នុងន័យទូលាយ។

**រូបភាពទី 2៖សន្ទស្សន៍តម្លៃនាំចូល ផលិតផលសម្លៀកបំពាក់ពីប្រទេសសមាជិកអាស៊ាន (2012=100)**




ប្រភព៖ នាយកដ្ឋានពលកម្មរបស់សហរដ្ឋអាមេរិក

សន្ទស្សន៍តម្លៃនាំចូលសម្រាប់ទីផ្សារគោលដៅដូចជា សហរដ្ឋអាមេរិក និង អឺរ៉ុប អាចប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់និន្នាការតម្លៃ ដែលអង្កេតឃើញក្នុងទិន្នន័យនាំចេញ។ សហរដ្ឋអាមេរិកមិនបានចេញផ្សាយសន្ទស្សន៍តម្លៃនាំចូលពីកម្ពុជាដោយជាក់លាក់ទេ ក៏ប៉ុន្តែ បានចេញផ្សាយអំពីសន្ទស្សន៍តម្លៃសម្រាប់ប្រទេស សហគមអាស៊ានទាំងមូល។ សន្ទស្សន៍តម្លៃនាំចូលរបស់សហរដ្ឋអាមេរិក ពីប្រទេសសហគមអាស៊ានបង្ហាញនូវសណ្ឋានប្រហាក់ប្រហែលគ្នាទៅនឹងទិន្នន័យរបស់កម្ពុជា។

តម្លៃនាំចូលសម្លៀកបំពាក់ពីសហរដ្ឋអាមេរិកពីប្រទេសតំបន់អាស៊ានធ្លាក់ចុះប្រមាណ 2.1 ភាគរយរវាងឆ្នាំ 2012 និង ត្រីមាសទីមួយឆ្នាំ 2016។ ក្នុងចំណោមប្រទេសទាំង 10 នៃសមាជិកអាស៊ាន កម្ពុជាគឺជាប្រទេសនាំចេញផលិតផលតម្បាញនិងសម្លៀកបំពាក់ធំបំផុតទីបី ទៅកាន់សហរដ្ឋអាមេរិក (បន្ទាប់ពីប្រទេសវៀតណាម និង ឥណ្ឌូនេស៊ី)[3]។ ដូចនេះសន្ទស្សន៍តម្លៃនាំចេញរបស់សហគមអាស៊ាន ហាក់ដូចមានការឆ្លុះបញ្ចាំងពីនិន្នាការតម្លៃផ្តល់ដល់អ្នកនាំចេញកម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ វាបានបញ្ជាក់ពីនិន្នាការដែលបានអង្កេតឃើញក្នុងស្ថិតិនាំចេញរបស់កម្ពុជា។

សន្ទស្សន៍តម្លៃនាំចូលទៅកាន់សហរដ្ឋអាមេរិកពីសហគមអាស៊ាន ដូចក្នុងរូបទី 2 គឺជាសូចនាករវាស់វែងយោង (proxy) ដែលប្រហាក់ប្រហែលខ្លាំងទៅនឹងតម្លៃសម្លៀកបំពាក់កម្ពុជា។ ទោះជាយ៉ាងនេះក្តី ស៊េរីទិន្នន័យនេះចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ 2012 ប៉ុណ្ណោះ។ សម្រាប់ទិដ្ឋភាពរយៈពេលវែងសម្រាប់តម្លៃក្នុងវិស័យកាត់ដេរ យើងអាចធ្វើការពិនិត្យមើលសន្ទស្សន៍តម្លៃនាំចូល ទូទៅរបស់សហរដ្ឋអាមេរិក និងសហគមអឺរ៉ុប[4] ដូចបានបង្ហាញក្នុងរូបទី 3។

សន្ទស្សន៍តម្លៃនាំចូលផលិតផលសម្លៀកបំពាក់បានកើនឡើង 11.9 ភាគរយរវាងឆ្នាំ 2006 និង 2015 ។ ភាគច្រើននៃកំណើននេះកើតមានក្នុងអំឡុងឆ្នាំ 2010 និង 2012។សន្ទស្សន៍នេះបាននៅទ្រឹងតាំងពីឆ្នាំ 2012 ដោយមានការធ្លាក់ចុះបន្តិចក្នុងប៉ុន្មានខែចុងក្រោយនេះ។ សន្ទស្សន៍របស់សហគមអឺរ៉ុប បានបង្ហាញនិន្នាការ

[3] នាយកដ្ឋានពាណិជ្ជកម្មសហរដ្ឋអាមេរិក

[4] សហភាពអឺរ៉ុប គឺសំដៅលើប្រទេសសមាជិកទាំង19 ដែលប្រើប្រាស់លុយ អឺរ៉ូ រួមមាន៖ ប្រទេល បែលហ្សិក អាល្លឺម៉ង់ អៀកឡង់ ក្រិក អេស្ប៉ាញ បារាំង អ៊ីតាលី ស៊ីពរ៍ លុចហ្សំបួរ ម៉ាល់តា ហុល្លង់ អូទ្រីស ព័រទុយហ្កាល់ ស្លូវ៉ានី ស្លូវ៉ាគី ហ្វាំងឡង់ អេស្តូនី ឡាត់វីយ៉ា និង លីទុយអានី

ប្រហាក់ប្រហែលនេះដែរ គឺមានការកើនឡើង 14 ភាគរយ រវាងឆ្នាំ 2006 និង 2015។

និន្នាការតម្លៃរបស់ផលិតផលស្បែកជើងមានភាពប្រសើរជាង បើមើលពីជ្រុងប្រទេសអ្នកផលិត។ ទោះជាកំណើនយឺតក្នុងរយៈពេលប៉ុន្មានឆ្នាំនេះក៏ដោយ តម្លៃស្បែកជើងនាំចូលទៅកាន់សហរដ្ឋអាមេរិកបានកើនឡើង 21.2 ភាគរយ រវាងឆ្នាំ 2006 និង 2015 ។

**រូបភាពទី 3៖ សន្ទស្សន៍តម្លៃនាំចូលផលិតផលសម្លៀកបំពាក់មកកាន់សហរដ្ឋអាមេរិក និង សហគមអឺរ៉ុប(2012=100)**




កត្តាជាច្រើនអាចពន្យល់បានពីភាពរអាក់រអួលនៃកំណើនតម្លៃ ក្នុងនេះមានកំណើនភាពប្រកួតប្រជែងក្នុងចំណោមប្រទេសផលិតសម្លៀកបំពាក់តម្រូវការទាប ការធ្លាក់ចុះនៃតម្លៃរូបិយបណ្ណរបស់ប្រទេសប្រកួតប្រជែង និងការរាលដាលនៃការបញ្ចុះតម្លៃនិងការផ្សព្វផ្សាយលក់។ គេឃើញមានការធ្លាក់ចុះតម្លៃវត្ថុធាតុដើមផងដែរ ដូចជាកប្បាស និង ប្រេងឥន្ធនៈ[5] ប្រសិនបើការធ្លាក់ចុះនៃតម្លៃសម្លៀកបំពាក់ត្រូវបានទូទាត់ដោយការធ្លាក់ចុះនៃតម្លៃនាំចូលវត្ថុធាតុដើម នោះផលិតករនឹងមិនរ៉ាប់រងទំងន់នៃការធ្លាក់ចុះតម្លៃសម្លៀកបំពាក់ទាំងស្រុងនោះទេ។

**រូបភាពទី 4៖ សន្ទស្សន៍តម្លៃនាំចូលផលិតផលស្បែកជើងមកកាន់សហរដ្ឋអាមេរិក (2012=100)**




ប្រភព៖ នាយកដ្ឋានពលកម្មរបស់សហរដ្ឋអាមេរិក

## 2. កម្រិតតម្លៃសម្រាប់ការនាំចេញសម្លៀកបំពាក់និងស្បែកជើង

តម្លៃមធ្យមដែលផ្តល់ដល់អ្នកនាំចេញកម្ពុជាបានធ្លាក់ចុះទាំងនៅក្នុងទីផ្សារសហរដ្ឋអាមេរិក និង សហភាពអឺរ៉ុបក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះដូចបង្ហាញក្នុងរូបភាពទី 1។ ទោះជាយ៉ាងនេះក្តី ឧស្សាហកម្មកម្ពុជាបានជាត់ទូទាត់ជាមួយនឹងការធ្លាក់ចុះនៃថ្លៃរបស់ទីផ្សារធំៗ ដោយការបង្វែទិសដៅនាំចេញ ពីសហរដ្ឋអាមេរិកទៅ សហភាពអឺរ៉ុប។ ជាមធ្យម តម្លៃនៃការនាំចេញពីកម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប គឺមានចំនួន 1.5 ដងនៃតម្លៃនាំទៅកាន់សហរដ្ឋអាមេរិក ដូចបង្ហាញនៅក្នុងរូបភាពទី5[6] ។

ការផ្លាស់ប្តូរទិសដៅនៃការនាំចេញពីកម្ពុជា បានជួយកាត់បន្ថយផលវិបាកពីការធ្លាក់ចុះនៃតម្លៃក្នុងចំណោមទីផ្សារនាំចេញ ដោយចំណែកភាគច្រើនត្រូវបាននាំទៅកាន់សហភាពអឺរ៉ុបដែលអាចផ្តល់តម្លៃជាមធ្យមខ្ពស់ជាង។ សហភាពអឺរ៉ុប បានផ្តល់អោយកម្ពុជានូវ ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម "ទំនិញគ្រប់យ៉ាងលើកលែងអាវុធ" ដោយក្នុងនោះកម្ពុជាបានទទួល

[5] យោងតាមធនាគារពិភពលោក តម្លៃកប្បាសបានធ្លាក់ចុះប្រមាណ 8.1 ភាគរយក្នុងឆ្នាំ 2014 ហើយប្រមាណ 15.3 ភាគរយក្នុងឆ្នាំ 2015 ស្រដៀងគ្នានេះដែរ តម្លៃមធ្យមរបស់ប្រេងនៅបានធ្លាក់ចុះប្រមាណ 7.5 ភាគរយ នៅក្នុងឆ្នាំ 2014 និង 47.3 ភាគរយក្នុងឆ្នាំ 2015។ តម្លៃប្រេងនៅនៅទីនេះ សំដៅលើតម្លៃ spot price របស់ Brent នៅប្រទេសឌុយបៃ និង West Texas Intermediate ហើយបានគណនាដោយមានទំងន់ត្រឹមត្រូវ (តម្លៃផលិតផល ដោយធនាគារពិភពលោក)

[6] អង្គការអន្តរជាតិខាងការងារ បានធ្វើការគណនាដោយផ្អែកលើទិន្នន័យមកពី អគ្គនាយកដ្ឋានពន្ធគយនិងអាករ។ ទិន្នន័យទទួលបានពីក្រសួងពាណិជ្ជកម្ម ក៏មានមធ្យមភាគប្រហាក់ប្រហែលនេះដែរ។

ការលើកលែងពន្ធ និង កូតា នូវរាល់ការនាំចូលទៅកាន់ទីផ្សារអឺរ៉ុប។ ទាំងនេះបានជួយដល់ ការផ្លាស់ប្តូរទីផ្សារនាំចេញ។ ការផ្លាស់ប្តូរទិសដៅនៃការនាំចេញពីកម្ពុជា បានជួយកាត់បន្ថយផលវិបាកពីការធ្លាក់ចុះនៃតម្លៃក្នុងចំណោមទីផ្សារនាំចេញ។

**រូបភាព ទី 5៖ តម្លៃមធ្យមក្នុងមួយឯកតា (តម្លៃបច្ចុប្បន្នគិតជា ដុល្លារអាមេរិកក្នុងមួយឡូ) នៃការនាំចេញសម្លៀកបំពាក់ពីកម្ពុជាទៅកាន់ទីផ្សារធំៗ***




ប្រភព៖ អគ្គនាយកដ្ឋានពន្ធគយ និង អាករ (GDCE)

* សំដៅលើតម្លៃមធ្យមនៃផលិតផលសម្លៀកបំពាក់គ្រប់ប្រភេទ

ការនាំចេញសម្លៀកបំពាក់ពីកម្ពុជាត្រូវបានលក់នៅក្នុងតម្លៃមួយទាបបើធៀបទៅនឹង ប្រទេសដ៏ទៃ។ ជាឧទាហរណ៍ រូបភាពទី 6 បានបង្ហាញពីថ្លៃដើមនាំចូលជាមធ្យមនៃសម្លៀកបំពាក់មួយប្រភេទទៅកាន់សហរដ្ឋអាមេរិក គឺជាតម្លៃមធ្យមដែលកម្ពុជាទទួលបានសម្រាប់ប្រភេទផលិតផលនេះ ហើយដែលទាបជាងគេបំផុតក្នុងបណ្តាលប្រទេសនាំចេញនៅអាស៊ី។

**រូបភាព ទី 6៖ តម្លៃមធ្យម (គិតជា ដុល្លារអាមេរិកក្នុងមួយឡូ) នៃអាវកូតុងសម្រាប់នារីទិញដោយអ្នកបញ្ជាទិញអាមេរិក***




ប្រភព ៖ នាយកដ្ឋានពាណិជ្ជកម្មសហរដ្ឋអាមេរិក

*សំដៅលើតម្លៃមធ្យមនៃអាវកូតុងសម្រាប់នារី (ប្រភេទ 339 និង 341) បញ្ជាទិញដោយអាមេរិក

## 3. ផលប៉ះពាល់នៃនិន្នាការតម្លៃតាមរយៈប្រាក់ឈ្នួលនិងលក្ខខណ្ឌការងារ

និន្នាការតម្លៃសម្លៀកបំពាក់បានការបង្កប់ន័យសំខាន់សម្រាប់ប្រាក់ឈ្នួលនិងលក្ខខណ្ឌការងារនៅក្នុងសង្វាក់ផ្គត់ផ្គង់ វិស័យកាត់ដេរនិងស្បែកជើង។ និយាយបែបទូលាយ មានមធ្យោបាយបីយ៉ាងដែលអាចរ៉ាប់រងការកើនឡើងនៃប្រាក់ឈ្នួល៖

- ដោយការបង្កើនតម្លៃផលិតផល
- ដោយការកាត់បន្ថយចំណែកតម្លៃបន្ថែមសម្រាប់ប្រាក់ចំណេញរបស់រោងចក្រ និង/ឬ
- ដោយការបង្កើនផលិតភាពការងារ

ប្រសិនបើតម្លៃនៅថេរ នោះត្រូវមានការកាត់បន្ថយចំណែកប្រាក់ចំណេញ និង/ឬ បង្កើនផលិតភាពការងារប្រសិនបើប្រាក់ឈ្នួលត្រូវបន្តកើនឡើងសម្រាប់កម្មករនិយោជិត។

ប្រាក់ឈ្នួលនៅក្នុងវិស័យកាត់ដេរ និង ស្បែកជើងកម្ពុជាបានកើនឡើងលឿនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បន្ទាប់ពីមានការនៅទ្រឹងរយៈពេលយូរ នៃតម្លៃពិត។ ប្រាក់ឈ្នួលអប្បបរមាតម្លៃពិត(ក្រោយពេលទូទាត់ជាមួយអតិផរណា) រួមទាំងអត្ថប្រយោជន៍ចាំបាច់ផ្សេងៗ បានកើនឡើងពីរដងក្នុងឆ្នាំ 2016 បើធៀបទៅនឹងប្រាំឆ្នាំមុន ដូចឃើញក្នុងរូបទី 7។

**រូបភាព ទី 7 ៖ ប្រាក់ឈ្នួលអប្បបរមាតម្លៃបច្ចុប្បន្ននិងតម្លៃពិត (វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង)**




ប្រភព៖ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និង សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ CPI (ពីវិទ្យាស្ថានជាតិស្ថិតិ)

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រាក់ចំណេញរបស់រោងចក្រហាក់មានការធ្លាក់ចុះគិតជាចំណែកនៃតម្លៃបន្ថែមដែលជាលទ្ធផលនៃកំណើនលឿនរបស់ប្រាក់ឈ្នួល។ ការរួញចុះនៃចំណែកប្រាក់ចំណេញបានកើតឡើងក្រោយរយៈពេលមួយវែងក្នុងទសវត្សឆ្នាំ 2000 ដែលពេលនោះប្រាក់ឈ្នួលអប្បបរមាតម្លៃពិតធ្លាក់ចុះ រីឯចំណែកប្រាក់ចំណេញដូចជាមានការកើនឡើង។

ទោះជាមានលទ្ធភាពក្នុងការរ៉ាប់រងកំណើនប្រាក់ឈ្នួល ដោយសារកាត់បន្ថយចំណែកប្រាក់ចំណេញក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្តី ការកាត់បន្ថយនេះមិនអាចបន្តដោយគ្មានកាលកំណត់នោះទេ។ អ្នកវិនិយោគ ត្រូវការអត្រាប្រាក់ចំណេញណាមួយពីការបណ្តាក់ទុនរបស់គេ ប្រសិនបើគេមិនអាចទទួលបានអត្រានោះទេ ពួកគេនឹងមិនបន្តវិនិយោគក្នុងវិស័យកាត់ដេរនៅកម្ពុជាទេ។ ដូចនេះអាចថា នៅពេលអនាគត កំណើនប្រាក់ឈ្នួលត្រូវតែរ៉ាប់រងដោយ ការបង្កើនផលិតភាពការងារឬ កំណើនតម្លៃផលិតផលសម្រេច ឬទាំងពីរ។

នៅពេលផលិតភាពការងារកើន នោះគេអាចបង្កើនលទ្ធភាពក្នុងការផ្តល់ប្រាក់ឈ្នួលខ្ពស់ជាងមុន។ ផលិតភាពការងារសំដៅលើតម្លៃបន្ថែមតម្លៃពិតរបស់វិស័យ ធៀបជាមួយនឹងចំនួនកម្មករនិយោជិតបម្រើការក្នុងវិស័យនេះ។ ប្រសិនបើផលិតភាពការងារកើន ឧទាហរណ៍កើន 5% ភាគរយ ហើយប្រាក់ឈ្នួល[7] តម្លៃពិត[8] កើន 5% ភាគរយ នោះចំណែកតម្លៃបន្ថែមដែលទទួលបានដោយកម្មករនិយោជិតនិងចំណែកប្រាក់ចំណេញ [9] ទទួលដោយនិយោជកនឹងមិនមានភាពខុសគ្នាទេ។

យោងតាមទិន្នន័យវិទ្យាស្ថានជាតិស្ថិតិ (NIS) ផលិតភាពការងាររបស់វិស័យកាត់ដេរនិងស្បែកជើងកម្ពុជាបានកើនឡើងក្នុងអត្រាសមាសប្រចាំឆ្នាំ 2.2 ភាគរយ រវាងឆ្នាំ 2003 និង 2015។ ជាលទ្ធផល ផលិតភាពការងាររបស់វិស័យបានកើនឡើង 30.1 ភាគរយក្នុងឆ្នាំ 2015 ធៀបនឹង 2003។

**រូបភាពទី 8៖ ផលិតភាពការងារនៅក្នុងវិស័យកាត់ដេរនិងស្បែកជើងកម្ពុជា (សន្ទស្សន៍ 2003 = 100)**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិកម្ពុជា គណនីជាតិ (តួលេខបឋមសម្រាប់ឆ្នាំ 2015) ក្រសួងពាណិជ្ជកម្ម

អត្រាកំណើនផលិតភាពបានចាប់ផ្តើមថយចុះនៅឆ្នាំ 2011 ហើយក្លាយជាអវិជ្ជមាននៅឆ្នាំខ្លះ។ ផលិតភាពការងារ ត្រូវបានប៉ាន់

[7] ‘តម្លៃពិត’ នៅទីនេះសំដៅលើប្រាក់ឈ្នួលដែលទូទាត់(deflated)ដោយសន្ទស្សន៍តម្លៃផលិតផលសម្រេច។

[8] ‘ប្រាក់ឈ្នួល’ នៅទីនេះសំដៅលើការចំណាយលើកម្មករនិយោជិតសរុប។

[9] ‘ប្រាក់ចំណេញ’ នៅទីនេះសំដៅលើអតិរេកប្រតិបត្តិការ (gross operating surplus)។

ស្ថានថានឹងកើនប្រមាណ 0.2% ភាគរយក្នុងឆ្នាំ 2015 ដោយយោងលើតួលេខបឋម[10]។ ដើម្បីធានាអោយមាននិរន្តភាពកំណើនប្រាក់ឈ្នួលតម្លៃពិត វាមានភាពចាំបាច់ដែលត្រូវអោយមានកំណើនផលិតភាព។ គេឃើញថានៅមានលទ្ធភាពបង្កើនផលិតភាពការងារដោយហេតុថាផលិតភាពនៅក្នុងវិស័យកាត់ដេរ តម្បាញនិងស្បែកជើងកម្ពុជានៅទាបជាងប្រទេសជាច្រើននៅឡើយ ដូចបង្ហាញក្នុងរូបទី 9។

**រូបភាពទី 9៖ ផលិតភាពការងារមធ្យមនៅក្នុងវិស័យកាត់ដេរ តម្បាញ និងស្បែកជើង (US$) ឆ្នាំចុងក្រោយបង្អស់ដែលមានទិន្នន័យ**




សម្គាល់៖ ផលិតភាពការងារគឺត្រូវបានកំណត់ដោយតម្លៃបន្ថែមដុលគិតជាតម្លៃបច្ចុប្បន្នក្នុងកម្មករនិយោជិតម្នាក់ គណនាជាដុល្លារអាមេរិក ដោយអត្រាប្តូរប្រាក់ផ្លូវការតម្លៃបច្ចុប្បន្ន។ តួលេខមធ្យមថ្នាក់វិស័យវាស់វែងដោយវិធីសាស្រ្តដូចគ្នាសម្រាប់ប្រទេសទាំងអស់។

ប្រភព៖ P. Huynh: *ILO Asia-Pacific Garment and Footwear Sector Research Note*ច្បាប់ទី I (ក្រុងបាងកក អង្គការអន្តរជាតិខាងការងារ វិច្ឆិកា 2015)

រូបទី 9 ស្តែងអោយឃើញនូវ គម្លាតផលិតភាព រវាងកម្ពុជានិងប្រទេសមួយចំនួនដែលនាំចេញសម្លៀកបំពាក់ដូចជា ថៃ ហ្វីលីពីន និង ឥណ្ឌូនេស៊ី។ ការបង្រួមគម្លាតនេះមានសារៈសំខាន់ព្រោះ នឹងធ្វើអោយកម្មករនិយោជិតកម្ពុជាអាចរីករាយនឹងកំណើនប្រាក់ឈ្នួលតម្លៃពិតក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ គេឃើញមានយុទ្ធសាស្រ្តច្រើនយ៉ាងដើម្បីបង្កើនផលិតភាព។ ទំនាក់ទំនងវិជ្ជាជីវៈល្អ អាចជាកត្តាសំខាន់មួយដែលជំរុញអោយមានកំណើនផលិតភាព។ ការវិនិយោគមូលធន និង បំលាស់ប្តូរបច្ចេកទេសក៏ជាកត្តាសំខាន់ដែរ ដូចជាជំនាញ សម្រាប់ទាំងអ្នកគ្រប់គ្រងនិងកម្មករនិយោជិត[11]។

ការផ្លាស់ប្តូរថ្មីៗលើ សោហ៊ុយដឹកជញ្ជូន និងលើកដាក់នៅកំពង់ផែអាចជួយដល់ភាពប្រកួតប្រជែងនៃការនាំចេញសម្លៀកបំពាក់ពីកម្ពុជា។ នៅថ្ងៃទី1 ខែឧសភា ឆ្នាំ 2016 សម្តេចនាយករដ្ឋមន្រ្តីបានប្រកាសជាផ្លូវការថា [12] ការកាត់បន្ថយថ្លៃសេវាលើកដាក់នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ 10 ភាគរយ[13] (ចូលជាធរមាននៅថ្ងៃទី 1 ខែឧសភា ឆ្នាំ2016) និងនៅកំពង់ផែស្វយ័តក្រុងភ្នំពេញ 5 ភាគរយ[14] (ចូលជាធរមាននៅថ្ងៃទី 16 ខែឧសភា ឆ្នាំ2016 )។ ភ្នាក់ងារកម្ពុជានាវាចរ (KAMSAB) ក៏បានកាត់បន្ថយសេវាថែមម៉ោងកុងតេន័រប្រមាណ 10 ភាគរយ[15] (ចូលជាធរមាននៅថ្ងៃទី 16 ខែឧសភា ឆ្នាំ2016)។ ការកាត់បន្ថយសោហ៊ុយទាំងនេះបានជួយដោះស្រាយបញ្ហាប្រឈម ផលិតភាព និង ភាពប្រកួតប្រជែងនៅកម្ពុជា។

គេឃើញមាន ឱកាសសម្រាប់បង្កើនផលិតភាពក្នុងវិស័យនេះ។ ហើយការបង្កើនផលិតភាពនេះ ក៏ជាឱកាសសម្រាប់បង្កើនប្រាក់ឈ្នួលតម្លៃពិតផងដែរ។ ទោះជាយ៉ាងនេះក្តី សម្រាប់ការកើនឡើងខ្ពស់នៃប្រាក់ឈ្នួលតម្លៃពិតនៅថ្ងៃអនាគត វាចាំបាច់តម្រូវអោយមានការបង្កើនតម្លៃសម្រាប់សម្លៀកបំពាក់និងស្បែកជើងនាំចេញពីកម្ពុជា។

---

[10] សូមសម្គាល់ថាតួលេខផលិតភាពនេះប្រើប្រាស់ទិន្នន័យរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្មដើម្បីវាស់វែងចំនួនកម្មករនិយោជិតបម្រើការក្នុងវិស័យ។

[11] សម្រាប់ការពិភាក្សាបន្ថែម សូមអានការសិក្សាស្តីពីការវិភាគមុខរបរ “Cambodia: Addressing the Skills Gap” ដែលជារបាយការណ៍រួមរវាង អង្គការអន្តរជាតិខាងការងារនិងធនាគារអភិវឌ្ឍន៍អាស៊ី 2015។

[12] សម្តេចនាយករដ្ឋមន្រ្តីបានថ្លែងការតាមរយៈទូរទស្សន៍ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) នៅថ្ងៃទី 1 ខែឧសភាឆ្នាំ 2016 ក្នុងឱកាសទិវាពលកម្មអន្តរជាតិ

[13] លិខិតកំពង់ផែស្វយ័តក្រុងព្រះសីហនុលេខ #014 ថ្ងៃទី1ខែ ឧសភា ឆ្នាំ2016។

[14] លិខិតកំពង់ផែស្វយ័តក្រុងភ្នំពេញ លេខ #0462 ថ្ងៃទី2 ខែ ឧសភា ឆ្នាំ2016។

[15] លិខិតភ្នាក់ងារនាវាចរកម្ពុជា #249/16 ថ្ងៃទី2 ខែ ឧសភា ឆ្នាំ2016។

អ្នកបញ្ជាទិញនិងម្ចាស់ផ្លាកសញ្ញាអន្តរជាតិ បានទទួលស្គាល់ថា តម្លៃដែលពួកគេផ្តល់អោយសម្រាប់សម្លៀកបំពាក់និងស្បែកជើង មានការប៉ះពាល់ដល់ប្រាក់ឈ្នួលនិងលក្ខខណ្ឌការងារនៅកម្ពុជា។ នៅក្នុងខែកញ្ញា និង វិច្ឆិកា ឆ្នាំ 2014 មានលិខិតផ្ញើជូនរដ្ឋាភិបាលកម្ពុជា ដោយអ្នកបញ្ជាទិញធំៗ របស់ អឺរ៉ុប និង សហរដ្ឋអាមេរិក ដោយបង្ហាញការគាំទ្ររបស់គេដល់ការបង្កើនប្រាក់ឈ្នួលសមរម្យ ដោយមានការគិតគូរពីផលិតភាពការងាររបស់វិស័យ និង កំណើនប្រសិទ្ធិភាព[16]។

ដូចបានបង្ហាញក្នុងកំណត់សម្គាល់ពីមុន តម្លៃមធ្យមដែលផ្តល់អោយការនាំចេញសម្លៀកបំពាក់ពីកម្ពុជាមិនបានកើនឡើងទេក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ តម្លៃសម្លៀកបំពាក់ដែលទិញដោយអ្នកបញ្ជាទិញអាមេរិក និង អឺរ៉ុប បានបង្ហាញពីសញ្ញាចម្រុះនៅក្នុងត្រីមាសទីមួយឆ្នាំ 2016។ សន្ទស្សន៍តម្លៃនាំចូលចុងក្រោយបំផុត ពីនាយកដ្ឋានពលកម្មរបស់សហរដ្ឋអាមេរិក បានបង្ហាញថា តម្លៃសម្លៀកបំពាក់ដែលអាមេរិកនាំចូលពីប្រទេសសហគមអាស៊ានបានធ្លាក់ចុះប្រមាណ 0.7 ភាគរយ នៅក្នុងត្រីមាសទី1ឆ្នាំ 2016 (ធៀបទៅនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំ2015)។ តម្លៃសម្លៀកបំពាក់ដែលអឺរ៉ុបនាំចូលបានកើនឡើង 0.7 ភាគរយក្នុងរយៈពេលដូចគ្នា[17]។ និន្នាការតម្លៃថ្មីៗនេះ មិនបានចង្អុលបង្ហាញពីឱកាសសម្រាប់ការបង្កើនប្រាក់ឈ្នួលតម្លៃពិតនោះទេ ប្រសិនបើមិនមានការកាត់បន្ថយចំណែកនៃប្រាក់ចំណេញរបស់រោងចក្រ ឬ ការបង្កើនផលិតភាព។

ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត 630,000 នាក់នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងនៅកម្ពុជា បានកើនពី 128 ដុល្លារនៅក្នុងឆ្នាំ 2015 ទៅ 140 ដុល្លារក្នុងឆ្នាំ 2016។ នេះតំណាងអោយការកើនឡើង 9.4 ភាគរយ។ គម្រោងអង្គការអន្តរជាតិខាងការងារបានធ្វើការប៉ាន់ស្មានថា វានឹងបង្កើនប្រាក់ឈ្នួលសរុបប្រមាណ 8.2 លានដុល្លារ ក្នុងមួយខែ ឬ 97.9 លានដុល្លារក្នុងមួយឆ្នាំ។ ជាលទ្ធផលប្រាក់ឈ្នួលសរុបរបស់វិស័យត្រូវបាន់ស្មានថានឹងកើនឡើង 8.0 ភាគរយនៅឆ្នាំ 2016។

### 4. តួនាទីរបស់អ្នកប្រើប្រាស់

ភាពនៅទ្រឹង និងពេលខ្លះធ្លាក់ចុះនៃថ្លៃ បានធ្វើអោយអ្នកប្រើប្រាស់ទទួលបាននូវអត្ថប្រយោជន៍។ តម្លៃដែលផ្តល់ដោយអ្នកប្រើប្រាស់អាមេរិកចំពោះសម្លៀកបំពាក់ បានកើនឡើងតែ 5.4 ភាគរយប៉ុណ្ណោះ ក្នុងអំឡុងឆ្នាំ 2006 និង 2015[18]។ កំណើនតម្លៃសម្លៀកបំពាក់សម្រាប់អ្នកប្រើប្រាស់អឺរ៉ុបគឺដូចគ្នា 5.4 ភាគរយ។ នេះជាការកើនឡើងតិចតួចបំផុតក្នុងទសវត្សកន្លងទៅ[19]។

**រូបភាពទី 10៖ អតិផរណាតម្លៃទំនិញប្រើប្រាសសម្រាប់សម្លៀកបំពាក់នៅលើទីផ្សារ អឺរ៉ុប និង សហរដ្ឋអាមេរិក (2012=100)**




ប្រភព៖ នាយកដ្ឋានការងារសហរដ្ឋអាមេរិក

សម្គាល់៖ អតិផរណាតម្លៃសម្លៀកបំពាក់នៅអាមេរិកគឺមានការកែតម្រូវរៀងរាល់រដូវកាល ហើយតម្លៃនៅអឺរ៉ុបត្រូវបានគណនាដោយប្រើប្រាស់មធ្យមភាគ 12 ខែ (ក្រុមប្រទេស19 ដែលប្រើលុយអឺរ៉ូ)

[16] លិខិតពីអ្នកបញ្ជាទិញធំៗរបស់អាមេរិកផ្ញើរជូនរដ្ឋាភិបាលកម្ពុជា ថ្ងៃទី 10 ខែវិច្ឆិកា ឆ្នាំ 2014 និង លិខិតអ្នកបញ្ជាទិញធំៗរបស់អឺរ៉ុបផ្ញើរជូនរដ្ឋាភិបាលកម្ពុជា ថ្ងៃទី 18 ខែ កញ្ញា ឆ្នាំ 2014។ លិខិតនេះអាចរកអានបានតាម http://www.industriall-union.org/brands-say-they-will-pay-more-for-clothes-made-in-cambodia និង http://www.fairlabor.org/sites/default/files/letter_from_global_brands_on_wages_in_cambodia_nov_2014.pdf.

[17] យោងតាមសមាជិកទាំង 19 របស់ប្រទេសជាសមាជិក

[18] នាយកដ្ឋានការងាររបស់សហរដ្ឋអាមេរិក

[19] The Eurostat

## 5. សរុប

កំណើនប្រាក់ឈ្នួលអប្បបរមាខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ស្របជាមួយនឹងកំណើនផលិតភាពទាប ហាក់ដូចជាមិនបានកត់ត្រានូវផលប៉ះពាល់អវិជ្ជមានលើវិស័យនេះទេ ដោយហេតុថាការនាំចេញនិងចំនួនការងារនៅបន្តកើនឡើងយ៉ាងរឹងមាំ។ វាអាចជាករណីដែលថារោងចក្រមួយចំនួនអាចមានលទ្ធភាពកាត់បន្ថយ ប្រាក់ចំណេញរបស់គេ ដើម្បីរក្សាភាពបិតថេរ និងភាពទាក់ទាញរបស់គេ ក៏ប៉ុន្តែលទ្ធភាពក្នុងការកាត់បន្ថយប្រាក់ចំណេញទំនងជាកាន់តែតិចទៅនៅកម្រិតរោងចក្រ។ គេឃើញថាកំណើនផលិតភាពអាចនៅមាន ក៏ប៉ុន្តែការរំពឹងលើកំណើនផលិតភាពហាក់នឹងមិនកើនខ្ពស់ទេក្នុងរយៈពេលខ្លី។

ហេតុដូចនេះ ប្រសិនបើកម្មករនិយោជិតត្រូវទទួលបានកំណើនប្រាក់ឈ្នួលក្នុងវិស័យកាត់ដេរនិងស្បែកជើង និន្នាការតម្លៃនឹងមានភាពសំខាន់ខ្លាំងណាស់។ អ្នកបញ្ជាទិញនិងម្ចាស់ផ្លាកសញ្ញាអន្តរជាតិ ក៏ដូចជាអ្នកប្រើប្រាស់ មានតួនាទីក្នុងការធានាថាតម្លៃដែលពួកគេផ្តល់អោយ នឹងជំរុញអោយមាននិរន្តភាពការងារសមរម្យក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។

ការរំពឹងថាថ្លៃនឹងកើនឡើងខ្ពស់ ហាក់ដូចជានឹងមិនកើតឡើងក្នុងរយៈពេលខ្លីនោះទេ។ យោងតាមរបាយការណ៍ប៉ាន់ប្រមាណស្ថានភាពសេដ្ឋកិច្ច (World Economic Outlook July 2016) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ សេដ្ឋកិច្ចពិភពលោកអាចកើន 3.1 ភាគរយក្នុងឆ្នាំ 2016 ដែលដូចគ្នាកាលពីឆ្នាំ 2015។ សេដ្ឋកិច្ចអាមេរិក ត្រូវបានរំពឹងថានឹងកើនឡើង 2.2 ភាគរយ នៅក្នុងឆ្នាំ 2016 ធ្លាក់ចុះពី 2.4 ភាគរយ ក្នុងឆ្នាំ 2015 នៅពេលដែល តំបន់ប្រើលុយអឺរ៉ូត្រូវបានប៉ាន់ស្មានថាមានកំណើនយឺត 1.6 ភាគរយក្នុងឆ្នាំ 2016 ធៀបនឹងអត្រា 1.7 ភាគរយក្នុងឆ្នាំ 2015។ កំណើនសេដ្ឋកិច្ចខ្សោយរបស់អឺរ៉ុបនិងសហរដ្ឋអាមេរិក ដែលជាអ្នកបញ្ជាទិញសំខាន់របស់កម្ពុជា អាចកាត់បន្ថយការរំពឹងទុកអំពីកំណើនថ្លៃ និងជាកត្តាដែលរារាំងធ្វើអោយវិស័យនេះមិនអាចទ្រទ្រង់កំណើនខ្ពស់របស់ប្រាក់ឈ្នួល។

## ផ្នែកទី II ទិន្នន័យបច្ចុប្បន្នភាព

ព័ត៌មាននៅក្នុងផ្នែកទី I ខាងលើផ្តល់នូវការប្រមើលមើលអំពីនិន្នាការតម្លៃសម្រាប់ការនាំចេញពីកម្ពុជានិងការឆ្លុះបញ្ចាំងអំពីនិន្នាការប្រាក់ឈ្នួល និងលក្ខខណ្ឌការងារ។ ផ្នែកទីពីរ នៃព្រឹត្តិបត្រ នេះផ្តល់នូវព័ត៌មានបច្ចុប្បន្នភាពទៀងទាត់ទាក់ទងនឹងការវិវត្តថ្មីៗនៅក្នុងវិស័យនេះ។

វិស័យកាត់ដេរនិងស្បែកជើងកម្ពុជានៅតែជាកម្លាំងនាំមុខសំខាន់ក្នុងការនាំចេញទំនិញ ហើយក៏ជាប្រភពផ្តល់ការងារដ៏ធំ និងជាសសរស្តម្ភរបស់ប្រទេស។ កាលពីដើមឆ្នាំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើការប៉ាន់ស្មានថាសេដ្ឋកិច្ចកម្ពុជានឹងកើនប្រមាណ 6.9 ភាគរយក្នុងឆ្នាំ 2015 ហើយវិស័យកាត់ដេរនិងស្បែកជើងជាកត្តាចូលរួមក្នុងកំណើន [20]ធំបង្អស់។ វិស័យនេះជាកត្តាជំរុញកំណើនខ្លាំងជាងគេក្នុងឆ្នាំ 2015 ហើយគណនីជាតិបឋមដែលចងក្រងដោយវិទ្យាស្ថានជាតិស្ថិតិបានកត់ត្រាថាវិស័យកាត់ដេរនិងស្បែកជើងចូលរួម 1.8 ភាគរយ ក្នុងកំណើនផលិតផលជាតិសរុបក្នុងឆ្នាំ 2015[21] ។

## 6. ការនាំចេញសម្លៀកបំពាក់និងស្បែកជើង

ការនាំចេញផលិតផលសម្លៀកបំពាក់និងស្បែកជើងបានបន្តកើនឡើងនៅក្នុងត្រីមាសទីមួយក្នុងឆ្នាំ 2016 ការនាំចេញសម្លៀកបំពាក់បានកើនឡើង 14.7 ភាគរយ ឬ កើនដល់1,605 លានដុល្លារ នៅពេលដែលការនាំចេញស្បែកជើងកើន 12.9 ភាគរយ ឬកើនដល់ 168 លានដុល្លារ។ យោងតាមស្ថិតិនាំចេញរបស់អគ្គនាយកដ្ឋានពន្ធគយនិងអាករ (GDCE) ការនាំចេញសម្លៀកបំពាក់និងស្បែកជើងសរុបក្នុងត្រីមាសទីមួយ កើនដល់ 1.8 ពាន់លានដុល្លារ

[20] បទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីស្ថានភាពសេដ្ឋកិច្ចរបស់កម្ពុជា (ថ្ងៃទី18 ខែកុម្ភៈ ឆ្នាំ 2016)។

[21] ការគណនារបស់ អង្គការអន្តជាតិខាងការងារ យោងតាមតួលេខបឋមរបស់គណនីជាតិរបស់វិទ្យាស្ថានស្ថិតិ។

តំណាងអោយ កំណើន 14.5 ភាគរយ នៅក្នុងរយៈពេលដូចគ្នានៃឆ្នាំ 2015។

សហភាពអឺរ៉ុប (EU) បានបន្តតំណាងអោយទីផ្សារធំបំផុតសម្រាប់ការនាំចេញសម្លៀកបំពាក់និងស្បែកជើងពីកម្ពុជា ដែលបានស្រូបយក 45 ភាគរយនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងសរុបនៅក្នុងត្រីមាសទីមួយក្នុងឆ្នាំ 2016។ សហរដ្ឋអាមេរិកតំណាងអោយ 24 ភាគរយក្នុងរយៈពេលដូចគ្នានេះហើយនៅសល់ 31 ភាគរយគឺការនាំចេញទៅទីផ្សារដ៏ទៃសំខាន់គឺ កាណាដា និង ជប៉ុន។

**រូបភាពទី 11 ៖ ការនាំចេញសម្លៀកបំពាក់និងស្បែកជើងពីកម្ពុជា1995-2015** (លានដុល្លារ)




ប្រភព៖ អគ្គនាយកដ្ឋានពន្ធគយនិងរាករ

## 7. ការវិនិយោគថ្មីៗ ចំនួនរោងចក្របិទ និង បើក

**ក –ការវិនិយោគថ្មីៗ៖** ការវិនិយោគបរទេសទាំងក្នុងវិស័យប្រើប្រាស់ពលកម្មច្រើន និង វិស័យប្រើប្រាស់មូលធនច្រើន បានដើរតួនាទីសំខាន់ក្នុងការបង្កើតការងារ ដោយហេតុថារៀងរាល់ឆ្នាំមានអ្នកស្វែងរកការងាររាប់សែននាក់ឈានចូលទីផ្សារការងារ។ របាយការអង្កេតការអភិវឌ្ឍប្រចាំឆ្នាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ 2016 បានបង្ហាញអោយដឹងថា "កម្ពុជាផ្គត់ផ្គង់កំលាំងពលកម្មតម្លៃទាប និងជំនាញទាបដែលទាក់ទាញការវិនិយោគបរទេសយ៉ាងច្រើនក្នុងការផលិតសម្លៀកបំពាក់និងស្បែកជើងសម្រាប់នាំចេញ"[22]។

ការហូរចូលនៃការវិនិយោគបរទេសក្នុងវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងបានបន្តបង្ហាញសញ្ញាវិជ្ជមានក្នុងត្រីមាសទីមួយឆ្នាំ 2016 យោងតាមតួលេខផ្លូវការរបស់ក្រុមប្រឹក្សាភិបាលវិនិយោគកម្ពុជា(CIB) ទាំងចំនួនគម្រោងវិនិយោគនិងទាំងទំហំទឹកប្រាក់វិនិយោគ។ ក្នុងចំណោមគម្រោងវិនិយោគទាំង37 ដែលបានអនុម័តក្នុងត្រីមាសទីមួយឆ្នាំ 2016 មានគម្រោង 22 ដែលវិនិយោគក្នុងវិស័យកាត់ដេរនិងស្បែកជើង ដែលគម្រោងកាត់ដេរមានចំនួន 18 និង គម្រោងផលិតស្បែកជើង[23]ចំនួន4 ។

នៅពេលដែលមានគម្រោងវិនិយោគអនុម័តភាគច្រើនជាការវិនិយោគក្នុងវិស័យកាត់ដេរនិងស្បែកជើង ទំហំទឹកប្រាក់វិនិយោគនៅក្នុងវិស័យនេះមានតែ 9 ភាគរយប៉ុណ្ណោះ គិតជាទឹកប្រាក់។ នៅក្នុងត្រីមាសទីមួយនៃឆ្នាំ ទំហំទឹកប្រាក់វិនិយោគទាំងអស់មានចំនួន 955 លានដុល្លារ ក្នុងនោះមាន 86 លានដុល្លារជាការវិនិយោគក្នុងវិស័យកាត់ដេរនិងស្បែកជើង។ អនុបាតនេះមានភាពខ្ពស់ជាងក្នុងឆ្នាំ 2014 និង 2015 នៅពេលដែលគម្រោងវិនិយោគថ្មីក្នុងវិស័យកាត់ដេរនិងស្បែកជើងតំណាងអោយ 28 ភាគរយ និង 10 ភាគរយ នៃគម្រោងវិនិយោគថ្មីៗទាំងអស់។

គិតក្នុងតម្លៃជាច់ខាត វិស័យនេះបានកត់ត្រាកំណើន 20 ភាគរយធៀបទៅនឹងត្រីមាសដូចគ្នានៃឆ្នាំ 2015។ ការវិនិយោគក្នុងវិស័យកាត់ដេរនិងស្បែកជើងបានកើនឡើងយ៉ាងរឹងមាំ ក៏ប៉ុន្តែការវិនិយោគក្នុងវិស័យផ្សេងទៀតមានការកើនឡើងកាន់តែរហ័សជាងនេះទៅទៀតនៅពេលដែលមានពិពិធកម្មលំហូរការវិនិយោគផ្ទាល់ពីបរទេស។

[22] របាយការអង្កេតការអភិវឌ្ឍប្រចាំឆ្នាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ 2016 អាចអានបានលើគេហទំព័រ ធនាគារអភិវឌ្ឍន៍អាស៊ី(ថ្ងៃទី 11 ខែឧសភាឆ្នាំ 2016) http://www.adb.org/news/features/here-comes-cambodia-asia-s-new-tiger-economy

[23] ទាំងនេះជាគម្រោងដែលបំពេញតាមលក្ខណៈត្រឹមត្រូវ(QIP)។ មិនរាប់បញ្ចូលគម្រោងបច្ចុប្បន្នដែលពង្រីកបន្ថែម។

ទម្រង់លំហូរនៃការវិនិយោគផ្ទាល់បរទេសពីប្រទេសផ្សេងៗគឺនៅមានភាពស្រដៀងគ្នាកាលពីឆ្នាំមុន។ ការវិនិយោគក្នុងវិស័យកាត់ដេរនិងស្បែកជើងបានបន្តនាំមុខដោយវិនិយោគិនមកពីប្រទេសចិន (37ភាគរយ) តៃវ៉ាន់(ចិន)(12 ភាគរយ) ហុងកុង(ចិន)( 6 ភាគរយ) និង អង់គ្លេស (6 ភាគរយ)។ គម្រោងកាត់ដេរនិងស្បែកជើងភាគច្រើនដែលបានអនុម័តក្នុងត្រីមាសទីមួយនៃឆ្នាំ 2016 ជាទម្រង់ឯកកម្មសិទ្ធិ (85) និងសហកម្មសិទ្ធិ 15 ភាគរយ។

**ខ –ការបើក បិទ និងរោងចក្រកំពុងប្រត្តិបត្តិការ៖** ក្រសួងពាណិជ្ជកម្មបានរក្សាទិន្នន័យចំនួនរោងចក្រ។ ទិន្នន័យនេះបានប្រើប្រាស់ដោយអង្គការអន្តរជាតិខាងការងារ សម្រាប់ព្រឹត្តិបត្រព័ត៌មានច្បាប់នេះនិងច្បាប់មុនៗដើម្បីវាស់វែងចំនួនរោងចក្របើកនិងបិទ។ ក្នុងត្រីមាសទីមួយនៃឆ្នាំ 2016 ក្រសួងពាណិជ្ជកម្មបានដឹងថារោងចក្រមួយចំនូនមិនមានសកម្មភាព ហើយករណីខ្លះរោងចក្របានបិទទៅហើយតែមិនបានផ្តល់ដំណឹងផ្លូវការមកកាន់ក្រសួងដូចនេះទិន្នន័យមិនបានកត់ត្រាបម្រែបម្រួលនេះទេ។ ហេតុដូចនេះក្រសួង បានធ្វើការកែតម្រូវចំណាត់ថ្នាក់រោងចក្រកាត់ដេរនិងស្បែកជើងចំនួន 122 ដែលកំពុងបិទ និងបានបិទបណ្តោះអាសន្ន។

ជាលទ្ធផលនៃការកែតម្រូវនេះ ទិន្នន័យរបស់ក្រសួងបានបង្ហាញថារោងចក្រកាត់ដេរសម្លៀកបំពាក់និងស្បែកជើងចំនួន 12 ថ្មីបានបើក និង 122 បានបិទ ក្នុងត្រីមាសទីមួយនៃឆ្នាំ 2016។ ដូចនេះមានរោងចក្របិទសុទ្ធចំនួន 110 ក្នុងត្រីមាសទីមួយឆ្នាំ 2016 ក្នុងនោះរោងចក្រកាត់ដេរចំនួន 100 និង ស្បែកជើងចំនួន 10។ ចំនួនរោងចក្រកាត់ដេរនិងស្បែកជើងសរុប នៅចុងខែមិនា ឆ្នាំ 2016 មានចំនួន 589 រោងចក្រ ថយចុះពី 699 ក្នុងឆ្នាំ2015[24] ។ ទាំងនេះគួរមានការបញ្ជាក់ថាការធ្លាក់ចុះ គឺដោយសារមានការកែតម្រូវនៃកំណត់ត្រា មិនមែនដោយសារកំណើនពិតប្រាកដនៃការបិទរោងចក្រនោះទេ។ តួលេខនាំចេញ និង ចំនួនការងារបានបង្ហាញថាឧស្សាហកម្មនេះនៅតែបន្តកើនឡើង។

## 8. ចំនួនការងារនិងប្រាក់ឈ្នួល

ចំនួនការងារនៅក្នុងវិស័យកាត់ដេរនិងស្បែកជើងបានបន្តកើនឡើងនៅក្នុងត្រីមាសទីមួយនៃឆ្នាំ 2016 ដោយឈានដល់ប្រហែល 630,000 នាក់[25] តំណាងអោយកំណើន 5.3 ភាគរយធៀបនឹងត្រីមាសទីមួយឆ្នាំ 2015[26]។ ប្រាក់បៀវត្សសរុបសម្រាប់វិស័យបានបន្តកើនឡើង ដោយឈានដល់ 118 លានដុល្លារ ក្នុងមួយខែក្នុងត្រីមាសទីមួយឆ្នាំ 2016 ដោយកើនពី 109 លានដុល្លារក្នុងមួយខែក្នុងឆ្នាំ 2015។

ប្រាក់ឈ្នួលអប្បបរមាអនុវត្តតែនៅក្នុងវិស័យកាត់ដេរនិងស្បែកជើងប៉ុណ្ណោះ។ វានឹងមានការពិនិត្យសារឡើងវិញនូវប្រាក់ឈ្នួលអប្បបរមានៅចុងឆ្នាំ 2016។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីប្រកាសនៅថ្ងៃទី 6ខែមិថុនា ឆ្នាំ 2016 អំពីកាលបរិច្ឆេទលំអិតនៃការចរចារប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ 2017 ដូចខាងក្រោម៖

i. ខែកក្កដាឆ្នាំ 2016 តំណាងនិយោជកនិងកម្មករនិយោជិតនឹងចាប់ផ្តើមការពិភាក្សាផ្ទៃក្នុងរបស់ពួកគេ។
ii. ខែសីហាឆ្នាំ 2016 តំណាងនិយោជកនិងកម្មករនិយោជិតនឹងចាប់ផ្តើមការពិភាក្សាទ្វេរភាគី។
iii. ខែកញ្ញាឆ្នាំ 2016 កិច្ចសន្ទនាត្រីភាគីនឹងចាប់ផ្តើមធ្វើឡើងរវាងតំណាងរដ្ឋាភិបាល និយោជក និង កម្មករនិយោជិត និងចុងក្រោយ
iv. គណៈកម្មការត្រីភាគី (LAC) នឹងធ្វើការផ្តល់អនុសាសន៍ទៅដល់រដ្ឋាភិបាលអំពីអត្រាប្រាក់ឈ្នួលអប្បបរមា អត្រាដែលកែតម្រូវថ្មីនេះនឹងត្រូវដាក់អោយអនុវត្តពីថ្ងៃទី 1 ខែមករាឆ្នាំ 2017។

[24] ចំនួនរោងចក្រសំដៅលើរោងចក្រនាំចេញដែលបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មជាផ្លូវការប៉ុនណោះ។ រោងចក្រម៉ៅការមួយចំនួន(ដែលមិនបាននាំចេញផ្ទាល់ ហើយមិនបានចុះបញ្ជីផ្លូវការ) មិនត្រូវបានរាប់បញ្ចូលទេ។

[25] តួលេខប្រាក់ឈ្នួលមធ្យមត្រីមាសទីមួយឆ្នាំ2016។

[26] នេះជាតួលេខចំនួនការងារមធ្យមក្នុងមួយខែ ក្នុងត្រីមាសទីមួយឆ្នាំ2016 ដោយធៀបនឹងត្រីមាសទីមួយឆ្នាំ2015។

រូបភាពទី ១២៖ ចំនួនការងារ ប្រាក់ឈ្នួលអប្បបមារមធ្យមតម្លៃបច្ចុប្បន្ននិងតម្លៃពិត (សម្លៀកបំពាក់និងស្បែកជើង)




ប្រភព៖ ក្រសួងពាណិជ្ជកម្ម

ដូចបង្ហាញក្នុងរូបខាងលើ ប្រាក់ឈ្នួលអប្បបរមាតម្លៃពិតមធ្យមប្រចាំខែសម្រាប់កម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរនិងស្បែកជើងបន្តកើនឡើង នៅក្នុងត្រីមាសទីមួយឆ្នាំ 2016 ដោយប្រាក់ឈ្នួលអប្បបរមាមធ្យមប្រចាំខែ(ឬប្រាក់ខែយកទៅផ្ទះ) ឈានដល់ចំនួន 187 ដុល្លារក្នុងមួយខែ (ពី175 ដុល្លារក្នុងឆ្នាំ 2015)។ នៅក្នុងរយៈពេលនេះដែរ ប្រាក់ឈ្នួលតម្លៃពិត (នៅពេលដែលអត្រាអតិផរណាត្រូវបានកែតម្រូវ) កើនដល់ 160 ដុល្លារក្នុងមួយខែក្នុងត្រីមាសទីមួយឆ្នាំ 2016 (ដែលកើនពីកម្រិតមធ្យម 151ដុល្លារក្នុងមួយខែក្នុងឆ្នាំ) 2015។ ទោះបីជាប្រាក់ឈ្នួលមធ្យមផ្លូវការត្រូវបានកំណត់ 140 ដុល្លារក្នុងមួយខែក្នុងឆ្នាំ 2016 ប៉ុន្តែនៅពេល បូកបន្ថែមជាមួយអត្ថប្រយោជន៍ដ៏ទៃទៀត រង្វាន់និងប្រាក់ថែមម៉ោង ប្រាក់ខែដែលកម្មករនិយោជិកយកទៅផ្ទះគឺតែងតែមានចំនួន 35 ឬ 45 ភាគរយ ច្រើនជាងប្រាក់ឈ្នួលអប្បបរមា។ អត្រាអតិផរណាទាបក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានផ្តល់ប្រយោជន៍ដល់កម្មករនិយោជិតនូវកំណើនប្រាក់ឈ្នួលពិត។

## 9. បញ្ញត្តិថ្មីសម្រាប់វិភាគទានរបបសន្តិសុខសង្គម (បសស)

របបសន្តិសុខសង្គម (បសស) ជាគម្រោងសុវត្ថិភាពសង្គមដែលអនុវត្តដោយរដ្ឋាភិបាលគ្របដណ្តប់លើគ្រោះថ្នាក់ការងារ ជំងឺវិជ្ជាជីវៈ និងគ្រោះថ្នាក់ពេលធ្វើដំណើរទៅនិងមកកន្លែងការងារ ដែលដំណើរការតាំងពីពាក់កណ្តាលឆ្នាំ 2008។ និយោជកត្រូវចូលរួមបង់វិភាគទានបសស[27] 0.8 ភាគរយនៃប្រាក់ឈ្នួលដុលរបស់កម្មករនិយោជិត។ ចាប់ពីថ្ងៃទី 6 ខែមករា ឆ្នាំ 2016[28] មក បសស បានពង្រីកវិសាលភាពដើម្បីគ្របដណ្តប់ការថែទាំសុខភាពរបស់កម្មករនិយោជិត[29]បន្ថែមទៀត។ នៅថ្ងៃទី 13 ខែមិថុនា ឆ្នាំ 2016 ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចេញប្រកាស(#220) ដោយដាក់បញ្ចូលបន្ថែមវិភាគទានទាំងពីខាងនិយោជកនិងខាងនិយោជិត សម្រាប់គ្របដណ្តប់ការធានារ៉ាប់រងថែទាំសុខភាពរបស់កម្មករនិយោជិត។ ប្រកាសថ្មីនេះដាក់ជាកាតព្វកិច្ចអោយនិយោជកបង់វិភាគទាន 1.3 ភាគរយ នៃប្រាក់ឈ្នួលកម្មករនិយោជិតចូលទៅក្នុងគម្រោងបសស ដូចគ្នានេះដែរ កម្មករនិយោជិតត្រូវបង់ 1.3 ភាគរយនៃប្រាក់ឈ្នួលរបស់គេទៅក្នុងវិភាគទានបសស។

## 10. សរុប

វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងកម្ពុជាបានបន្តមានសន្ទុះនៅក្នុងត្រីមាសទីមួយនៃឆ្នាំ 2016 ជាមួយនឹងកំណត់ត្រាកំណើននាំចេញ 14.5 ភាគរយក្នុងរយៈពេលដូចគ្នានៃឆ្នាំ 2015 (អាស្រ័យលើទិន្នន័យនាំចេញរបស់នាយកដ្ឋានពន្ធគយនិងរាករ)។ ចំនួនរោងចក្រជាច្រើនដែលមិនមានសកម្មភាព(122 រោងចក្រ) បានបញ្ចូលទៅក្នុងចំណាត់ថ្នាក់ រោងចក្រកំពុងបិទ ឬ បិទបណ្តោះអាសន្ន ក្នុងអំឡុងត្រីមាសទីមួយនៃឆ្នាំ 2016។ ជាមួយគ្នានេះ ចំនួនរោងចក្រដែលកំពុងដំណើរការសកម្ម (រោងចក្រកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង) ដែលមានចំនួន 589 (ថយពី 699 រោងចក្រក្នុងឆ្នាំ 2015) ទោះជាយ៉ាងនេះក្តី ចំនួនកម្មករនិយោជិតជាមធ្យមនៅក្នុងវិស័យនេះបានបន្តកើនឡើង (ដោយអត្រា 5.3

[27] ប្រកាសលេខ #109 អំពីតាវកាលិកនៃហានិភ័យការងារ ចុះថ្ងៃទី 16 ខែមិថុនា ឆ្នាំ 2008 របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[28] អនុក្រិតរបស់រដ្ឋាភិបាលលេខ #01 ចុះថ្ងៃទី 1 ខែកមករា ឆ្នាំ 2016

[29] ប្រភេទនៃសេវាកម្មនិងជំងឺដែលត្រូវបានគ្របបណ្តប់ នឹងមានចែងលំអិតនៅក្នុងសេចក្តីប្រកាសដាច់ដោយឡែករបស់ក្រសួង។

ភាគរយក្នុងត្រីមាសទីមួយឆ្នាំ 2016 ធៀបទៅនឹងត្រីមាសទីមួយឆ្នាំ 2015 ឬ កំណើនតែ ។ ភាគរយបើធៀបទៅនឹងអត្រាមធ្យមប្រចាំឆ្នាំ 2015)។

ប្រាក់ឈ្នួលអប្បបរមាប្រចាំខែ និង ប្រាក់ឈ្នួលពិតបានបន្តកើនឡើងជាលំដាប់នៅក្នុងត្រីមាសទីមួយនៃឆ្នាំ 2016។ ក៏ប៉ុន្តែតម្លៃដែលផ្តល់អោយដោយអ្នកបញ្ជាទិញពីកម្ពុជាសំខាន់ៗ បង្ហាញសញ្ញាចម្រុះ ដោយហេតុថាតម្លៃនាំចូលសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិកធ្លាក់ចុះប្រមាណ 0.4 ភាគរយក្នុងត្រីមាសទីមួយឆ្នាំ 2016 (ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ 2015) ទន្ទឹមនឹងតម្លៃសម្លៀកបំពាក់នាំចូលដោយអ្នកបញ្ជាទិញអឺរ៉ុបកើនប្រហែល 0.7 ភាគរយក្នុងរយៈពេលដូចគ្នា។

## តារាងឧបសម្ព័ន្ធ 1. ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងកម្ពុជា – សូចនាករជម្រើស

| | 2014 | | | | | 2015 | | | | | 2016 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2014 | Q1 | Q1 | Q3 | Q4 | 2015 | Q1 | Q2 | Q3 | Q4 | 2016* |
| **1. ទិន្នផលសេដ្ឋកិច្ច** | | | | | | | | | | | | | | | |
| ផ.ស.ស (ផលិតផលសេដ្ឋកិច្ចសរុប % កំណើនពិត) | - | - | - | - | **7.1** | - | - | - | - | **6.9** | - | - | - | - | **7.2** |
| ផ.ស.ស (% កំណើនតម្លៃបច្ចុប្បន្ន) | - | - | - | - | **10.0** | - | - | - | - | **8.9** | - | - | - | - | **10.0** |
| ផ.ស.ស (តម្លៃបច្ចុប្បន្ន លានដុល្លារ) | - | - | - | - | **16 703** | - | - | - | - | **18 083** | - | - | - | - | **19 764** |
| តម្លៃបន្ថែម (សម្លៀកបំពាក់និងស្បែកជើង, តម្លៃបច្ចុប្បន្ន) | - | - | - | - | 1 683 | - | - | - | - | 1 915 | - | - | - | - | - |
| តម្លៃបន្ថែម (សម្លៀកបំពាក់និងស្បែកជើង គិតជា % នៃ ផ.ស.ស.) | - | - | - | - | 10.1 | - | - | - | - | 10.6 | - | - | - | - | - |
| **2. ការនាំចេញសម្លៀកបំពាក់និងស្បែកជើង** | | | | | | | | | | | | | | | |
| ***2ក. កំណើននៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងសរុប*** | | | | | | | | | | | | | | | |
| **ការនាំចេញសម្លៀកបំពាក់និងស្បែកជើង(លានដុល្លារ)** [1/] | **1 464** | **1 379** | **1 625** | **1 493** | **5 960** | **1 549** | **1 602** | **1 995** | **1 681** | **6 827** | **1 773** | - | - | - | - |
| % កំណើន (ធៀបនឹងឆ្នាំមុន) | 19.7 | 9.6 | 3.6 | 11.9 | **10.7** | 5.8 | 16.1 | 22.8 | 12.6 | **14.5** | 14.5 | - | - | - | - |
| ការនាំចេញសម្លៀកបំពាក់[1/] | 1 359 | 1 271 | 1 502 | 1 357 | **5 489** | 1 400 | 1 434 | 1 832 | 1 501 | **6 167** | 1 605 | - | - | - | - |
| % កំណើន (ធៀបនឹងឆ្នាំមុន) | 19.8 | 8.7 | 1.8 | 9.1 | **9.3** | 3.0 | 12.9 | 21.9 | 10.6 | **12.3** | 14.7 | - | - | - | - |
| ការនាំចេញស្បែកជើង | 105 | 109 | 122 | 135 | **471** | 149 | 168 | 163 | 180 | **660** | 168 | - | - | - | - |
| % កំណើន (ធៀបនឹងឆ្នាំមុន) | 19.2 | 20.1 | 33.1 | 50.6 | **30.8** | 41.7 | 54.4 | 33.6 | 33.0 | **40.0** | 12.9 | - | - | - | - |
| **ការនាំទំនិញចូលប្រើប្រាស់ក្នុងស្រុកនៃសម្ភារកាត់ដេរ(លានដុល្លារ)** | **-584** | **-672** | **-643** | **-671** | **-2 571** | **-616** | **-816** | **-813** | **-705** | **-2 949** | - | - | - | - | - |
| ***2ខ. ការនាំចេញសម្លៀកបំពាក់និងស្បែកជើង តាមគោលដៅសំខាន់ៗ*** | | | | | | | | | | | | | | | |
| **ការនាំចេញសម្លៀកបំពាក់និងស្បែកជើង(លានដុល្លារ)** | **1 464** | **1 379** | **1 625** | **1 493** | **5 960** | **1 549** | **1 602** | **1 995** | **1 681** | **6 827** | **1 773** | - | - | - | - |
| ទៅកាន់សហរដ្ឋអាមេរិក (សម្លៀកបំពាក់និងស្បែកជើង)[1/] | 531 | 452 | 511 | 469 | **1 964** | 491 | 494 | 585 | 439 | **2 009** | 429 | - | - | - | - |
| ទៅកាន់សហភាពអឺរ៉ុប (សម្លៀកបំពាក់និងស្បែកជើង)[1/] | 533 | 559 | 674 | 639 | **2 404** | 617 | 686 | 844 | 757 | **2 904** | 793 | - | - | - | - |
| ទៅកាន់ប្រទេសផ្សេងៗទៀត (សម្លៀកបំពាក់និងស្បែកជើង)[1/] | 400 | 368 | 440 | 385 | **1 593** | 440 | 422 | 566 | 486 | **1 914** | 550 | - | - | - | - |
| **ការនាំចេញសរុប(សម្លៀកបំពាក់លានដុល្លារ)**[1/] | **1 359** | **1 271** | **1 502** | **1 357** | **5 489** | **1 400** | **1 434** | **1 832** | **1 501** | **6 167** | **1 605** | - | - | - | - |

| | 2014 | | | | | 2015 | | | | | 2016 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2014 | Q1 | Q1 | Q3 | Q4 | 2015 | Q1 | Q2 | Q3 | Q4 | 2016* |
| ទៅកាន់សហរដ្ឋអាមេរិក (សម្លៀកបំពាក់)1/ | 512 | 437 | 494 | 446 | **1 889** | 462 | 461 | 557 | 408 | **1 888** | 400 | - | - | - | - |
| ទៅកាន់សហភាពអឺរ៉ុប (សម្លៀកបំពាក់)1/ | 482 | 500 | 616 | 575 | **2 173** | 546 | 600 | 768 | 670 | **2 583** | 714 | - | - | - | - |
| ទៅកាន់ប្រទេសផ្សេងៗទៀត (សម្លៀកបំពាក់)1/ | 365 | 334 | 392 | 337 | **1 427** | 392 | 373 | 508 | 424 | **1 696** | 491 | - | - | - | - |
| **ការនាំចេញសរុប(ស្បែកជើង លានដុល្លារ)** | **105** | **109** | **122** | **135** | **471** | **149** | **168** | **163** | **180** | **660** | **168** | - | - | - | - |
| ទៅកាន់សហរដ្ឋអាមេរិក (ស្បែកជើង) | 19 | 15 | 17 | 23 | **74** | 29 | 33 | 28 | 31 | **121** | 29 | - | - | - | - |
| ទៅកាន់សហភាពអឺរ៉ុប (ស្បែកជើង) | 51 | 59 | 58 | 64 | **231** | 72 | 86 | 76 | 86 | **321** | 79 | - | - | - | - |
| ទៅកាន់ប្រទេសផ្សេងៗទៀត (ស្បែកជើង) | 36 | 34 | 48 | 48 | **166** | 49 | 49 | 58 | 62 | **218** | 60 | - | - | - | - |
| 3. ការវិនិយោគថ្មី ការបើករោងចក្រ និង ការបិទរោងចក្រ | | | | | | | | | | | | | | | |
| *3ក. គម្រោងវិនិយោគថ្មី* | | | | | | | | | | | | | | | |
| **គម្រោងវិនិយោគសរុបដែលអនុម័តដោយក្រុមប្រឹក្សាវិនិយោគ** | **44** | **48** | **42** | **15** | **149** | **37** | **26** | **30** | **31** | 124 | 37 | - | - | - | - |
| ***ក្នុងនោះ*** **គម្រោងសម្លៀកបំពាក់ និង ស្បែកជើង1/** | **25** | **32** | **15** | **6** | **78** | **19** | **19** | **20** | **14** | 72 | 22 | - | - | - | - |
| គម្រោងកាត់ដេរ | 24 | 29 | 13 | 6 | 72 | 17 | 12 | 15 | 13 | 57 | 18 | - | - | - | - |
| គម្រោងស្បែកជើង | 1 | 3 | 2 | 0 | 6 | 2 | 7 | 5 | 1 | 15 | 4 | - | - | - | - |
| **គម្រោងសរុបដែលអនុម័តដោយក្រុមប្រឹក្សាវិនិយោគ (ជាលានដុល្លារ)** | **446** | **382** | **626** | **150** | **1 604** | **2 873** | **255** | **279** | **513** | 3 920 | 955 | - | - | - | - |
| ***ក្នុងនោះ*** **គម្រោងសម្លៀកបំពាក់ និង ស្បែកជើង (ជាលានដុល្លារ)1/** | **135** | **200** | **86** | **30** | **452** | **72** | **80** | **84** | **141** | 377 | 86 | - | - | - | - |
| គម្រោងកាត់ដេរ (ជាដុល្លារ) | 127 | 174 | 77 | 30 | 408 | 64 | 42 | 64 | 55 | 225 | 71 | - | - | - | - |
| គម្រោងស្បែកជើង (ជាដុល្លារ) | 7 | 27 | 9 | 0 | 44 | 8 | 38 | 20 | 86 | 151 | 15 | - | - | - | - |
| *3ខ. ការបើករោងចក្រ និង ការបិទរោងចក្រ 1/* | | | | | | | | | | | | | | | |
| **ចំនួនរោងចក្រកាត់ដេរ និង ស្បែកជើងសរុប (ចុងគ្រា)** | **548** | **576** | **597** | **626** | **626** | **640** | **655** | **680** | **699** | **699** | 589* | - | - | - | - |
| រោងចក្រកាត់ដេរ (ចុងគ្រា) | 488 | 515 | 532 | 558 | 558 | 572 | 585 | 607 | 626 | 626 | 526* | - | - | - | - |
| រោងចក្រស្បែកជើង (ចុងគ្រា) | 60 | 61 | 65 | 68 | 68 | 68 | 70 | 73 | 73 | 73 | 63* | - | - | - | - |
| **បើកសុទ្ធសរុប (សម្លៀកបំពាក់ និង ស្បែកជើង)1/** | **20** | **28** | **21** | **29** | **98** | **14** | **15** | **25** | **19** | **73** | -110* | - | - | - | - |
| រោងចក្រកាត់ដេរ | 19 | 27 | 17 | 26 | 89 | 14 | 13 | 22 | 19 | 68 | -100* | - | - | - | - |
| រោងចក្រស្បែកជើង | 1 | 1 | 4 | 3 | 9 | 0 | 2 | 3 | 0 | 5 | -10* | - | - | - | - |
| **បើក (សម្លៀកបំពាក់ និង ស្បែកជើង)** | **22** | **33** | **25** | **29** | **109** | **14** | **16** | **26** | **19** | **75** | 12 | - | - | - | - |
| រោងចក្រកាត់ដេរ | 20 | 31 | 21 | 26 | 98 | 14 | 14 | 23 | 19 | 70 | 10 | - | - | - | - |

| | 2014 | | | | | 2015 | | | | | 2016 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2014 | Q1 | Q1 | Q3 | Q4 | 2015 | Q1 | Q2 | Q3 | Q4 | 2016* |
| រោងចក្រស្បែកជើង | 2 | 2 | 4 | 3 | 11 | 0 | 2 | 3 | 0 | 5 | 2 | - | - | - | - |
| **បិទ (សម្លៀកបំពាក់ និង ស្បែកជើង)**[1/] | **2** | **5** | **4** | **0** | **11** | **0** | **1** | **1** | **0** | **2** | 122* | - | - | - | - |
| រោងចក្រកាត់ដេរ | 1 | 4 | 4 | 0 | 9 | 0 | 1 | 1 | 0 | 2 | 110* | - | - | - | - |
| រោងចក្រស្បែកជើង | 1 | 1 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 12* | - | - | - | - |
| **4. ការងារនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង** | | | | | | | | | | | | | | | |
| **កម្មករនិយោជិតកាត់ដេរ និង ស្បែកជើងសរុប (មធ្យមនៃពេល '000')** | **539** | **561** | **576** | **581** | **564** | **597** | **616** | **635** | **643** | **623** | 628 | - | - | - | - |
| % បម្រែបម្រួល (ធៀបនឹងឆ្នាំមុន) | 17.6 | 16.5 | 11.7 | 9.1 | 13.5 | 10.7 | 9.8 | 10.3 | 10.7 | 10.4 | 5.3% | - | - | - | - |
| កម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ (មធ្យមនៃពេល '000') | 454 | 475 | 484 | 488 | 475 | 500 | 516 | 533 | 538 | 522 | 525 | - | - | - | - |
| កម្មករនិយោជិតនៅក្នុងវិស័យស្បែកជើង (មធ្យមនៃពេល '000') | 85 | 87 | 92 | 93 | 89 | 97 | 101 | 102 | 106 | 101 | 103 | - | - | - | - |
| **5. ប្រាក់ឈ្នួល និង តម្លៃ** | | | | | | | | | | | | | | | |
| **ប្រាក់ឈ្នួលអប្បបរមា (វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើងលាន ដុល្លារ)** | **100**[2/] | **100** | **100** | **100** | **100** | **128** | **128** | **128** | **128** | **128** | 140 | - | - | - | - |
| **ប្រាក់ឈ្នួលមធ្យមប្រចាំខែ (កាត់ដេរសម្លៀកបំពាក់និងស្បែកជើង លានដុល្លា)**[4/] | **137** | **145** | **152** | **146** | **145** | **164** | **174** | **184** | **178** | **175** | 187 | - | - | - | - |
| ប្រាក់ឈ្នួលមធ្យមប្រចាំខែ (កម្មករនិយោជិតកាត់ដេរ)[3/] | 139 | 147 | 153 | 146 | 146 | 165 | 176 | 188 | 181 | 178 | 190 | - | - | - | - |
| ប្រាក់ឈ្នួលមធ្យមប្រចាំខែ (កម្មករនិយោជិតស្បែកជើង)[3/] | 127 | 137 | 149 | 146 | 140 | 157 | 165 | 166 | 165 | 163 | 173 | - | - | - | - |
| **ប្រាក់ឈ្នួលពិតមធ្យមប្រចាំខែ (សម្លៀកបំពាក់និងស្បែកជើង)**[4/ 5/] | **121** | **127** | **131** | **127** | **127** | **143** | **151** | **158** | **152** | **151** | 160 | - | - | - | - |
| ប្រាក់ឈ្នួលពិតមធ្យមប្រចាំខែ (សម្លៀកបំពាក់ ធ្នូ 2010)[3/ 4/] | 123 | 128 | 132 | 127 | 128 | 144 | 152 | 161 | 154 | 153 | 162 | - | - | - | - |
| ប្រាក់ឈ្នួលពិតមធ្យមប្រចាំខែ (ស្បែកជើង ធ្នូ 2010)[3/ 4/] | 113 | 119 | 129 | 127 | 122 | 137 | 143 | 142 | 141 | 141 | 148 | - | - | - | - |
| **សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (មធ្យមនៃពេល) គណនាឆ្នាំមូលដ្ឋានឡើងវិញខែធ្នូឆ្នាំ 2010=100** | **113.0** | **114.5** | **115.8** | **114.7** | **114.5** | **114.2** | **115.6** | **116.8** | **117.0** | **115.9** | **117.0** | **-** | **-** | **-** | **-** |
| **អត្រាអតិផរណា (មធ្យមនៃពេល កំណើនធៀបនឹងឆ្នាំមុន)** | **4.6%** | **4.8%** | **4.0%** | **2.1%** | **3.9%** | **1.0%** | **1.0%** | **0.8%** | **2.0%** | **1.2%** | 2.5% | - | - | - | - |

* ឆ្នាំ 2016 ជាការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

1/ រាប់បញ្ចូលវាយនភណ្ឌ។

2/ចូលជាធរមាន ថ្ងៃទី 1 ខែ កុម្ភៈ ឆ្នាំ 2014.

3/ ផ្អែកលើក្រសួងពាណិជ្ជកម្ម រាប់តែរោងចក្រកំពុងដំណើរការប៉ុណ្ណោះ។ ទិន្នន័យនេះ មិនរាប់បញ្ចូលនិយោជិតការិយាល័យបរទេស និង អ្នកគ្រប់គ្រងបរទេសទេ។

4/ ជាតម្លៃ ខែ ធ្នូ ឆ្នាំ 2010។

*/ សូមសម្គាល់ថាចំនួនភាគច្រើននៃកំណត់ត្រាបិទរោងចក្រគឺជាលទ្ធផលនៃការបែងចែកចំណាត់ថ្នាក់រោងចក្រ 'បិទ' ដែលបានបិទទ្វារក្នុងរយៈពេលប៉ុន្មានខែកន្លងទៅ។
ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និង ការគណនារបស់បុគ្គលិកអង្គការអន្តរជាតិខាងការងារ។

**ព័ត៌មានទំនាក់ទំនង**

ការិយាល័យអង្គការអន្តរជាតិខាងការងារ (ILO) ប្រចាំកម្ពុជា
ភ្នំពេញសិនធីរ អាគារ F ជាន់ទី 2
កាច់ជ្រុងមហាវិថីព្រះសីហនុ (274) និង មហាវិថីសុធារស (3)
រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: +855 23 220 817
Internet: www.ilo.org/asia
Email: huot@ilo.org


រក្សាសិទ្ធិ © អង្គការអន្តរជាតិខាងការងារ ឆ្នាំ 2016

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

*ព្រឹត្តិបត្រនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីដែលត្រូវបានគាំទ្រហិរញ្ញវត្ថុដោយអង្គការ GiZ តាងនាមឲ្យរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។ កម្មវិធីនេះ ត្រូវបានផ្តួចផ្តើមជាផ្នែកមួយនៃភាពជាដៃគូជាថ្មីមួយរវាងក្រសួងសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍អាល្លឺម៉ង់ (BMZ) និងអង្គការអន្តរជាតិខាងការងារ (ILO)។ ការទទួលខុសត្រូវលើយោបល់ទាំងឡាយដែលបានសម្តែងក្នុងព្រឹត្តិបត្រនេះ គឺស្ថិតទាំងស្រុងលើអ្នកនិពន្ធ ហើយការបោះពុម្ពផ្សាយព្រឹត្តិបត្រនេះ មិនមែនជាការយល់ព្រមរបស់អង្គការអន្តរជាតិខាងការងារ ឬ
រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ លើយោបល់ដែលត្រូវបានបង្ហាញនៅក្នុងព្រឹត្តិបត្រនេះទេ។*